# អង្គរបស់បណ្ឌិត

## ពាក្យបាលីបោរាណាចារ្យ

**សុ~ចិ~បុ~ភា~ဝិ~លិ~មុត្តោ　　ន ហិ សោ បណ្ឌិតោ ភវេ**
**ធរន្តោ ឆ ឥមេ ធម្មេ　　បុណ្ណចន្ទោវ សោភតិ ។**

**សុ**~មានក្នុងនរជនណា　　ព្យាយាមសិក្សាយ៉ាងហ្មត់ចត់
**ចិ**~ត្រិះរិះគិតយ៉ាងប្រាកដ　　ត្រិះរិះកំណត់យ៉ាងត្រឹមត្រូវ ។

**បុ**~ដេញដោលចោទជាពាក្យសួរ　　លើកនូវសំនួរដែលមាននូវ
ក្នុងចិត្តជាមន្ទិលដ៏សែនជ្រៅ　　អាចបើកជាផ្លូវឲ្យយល់បាន ។

**ភា**~ជួយបង្រៀនឬក៏ប្រាប់　　តាមក្បួនតាមច្បាប់ជាលំអាន
ដល់អ្នកដទៃឬមិត្រកល្យាណ　　នាំឲ្យចម្រើនថ្កាននូវបញ្ញា ។

**វិ**~វិនិច្ឆ័យយ៉ាងល្អិត　　ត្រិះរិះពិនិត្យពិចារណា
នូវពាក្យដែលខ្លួនបានសិក្សា　　នាំកាត់សង្កាទាំងនេះបាន ។

**លិ**~ពេលរៀនឬធ្វើការ　　ត្រូវតែកត់ត្រាពាក្យប៉ុន្មាន
កុំអាងសញ្ញាខ្លួនចាំបាន　　ក្បួនច្បាប់លំអានជាគ្រូពិត ។

នរជនមានធម៌ទាំង ៦　　នេះអាចលើកស្ទួយជាបណ្ឌិត
រុងរឿងថេរចាំងក្នុងជីវិត　　មិនវិប្បរិតវិបល្លាស ។

ព្រះចន្ទពេញបូណ៌មី　　មានរស្មីថ្វេងចាំងរះ
ពន្លឺភ្លឺថ្វេងច្បាស់　　មានឱកាសពេញលោកា ។

នរជនជាបណ្ឌិត　　ភ្លឺមែនពិតដោយបញ្ញា
រុងរឿងក្នុងលោកា　　សែនអស្ចារ្យជាងព្រះចន្ទ ។

# អត្ថន័យរបស់ពាក្យ

**សុ** ≈ **សុត** = *ការស្ដាប់, ការរៀន*

**ចិ** ≈ **ចិន្តន** =*ការត្រិះរិះគិត*

**បុ** ≈ **បុច្ឆន** =*ការសាកសួរ*

**ភា** ≈ **ភាសន** =*ការពោលបង្រៀន*

**វិ** ≈ **វិនិច្ឆយ** =*ការពិចារណា*

**លិ** ≈ **លិខន** =*ការសរសេរ, ការកត់ត្រា*

**ដោយលោកគ្រូ ធម្មានន្ទ**